ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ០៩២/១៤ - កូកូវ៉ុល អ៊ីតែរីល (ខេមបូឌា) អ៊ីន (សាខាទី២)
កាលបរិច្ឆេទនៃសេចក្តីបង្គាប់៖ ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៤

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **អ៊ឹង សុទ្ធី**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **លីវ សុវណ្ណា**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន កូកូវ៉ុល អ៊ីតែរីល (ខេមបូឌា) អ៊ីន (សាខាទី ២)**

អាសយដ្ឋាន ៖ ភូមិព្រៃព្រីងត្បូង សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០៧៨ ៨០៧ ០៨៧ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជកចូលរួមប្រជុំមុនសវនាការ ៖

- លោក ប៊ុន ផាណ្ណា អ្នកគ្រប់គ្រងទូទៅ

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ - **សហព័ន្ធសហជីពសាមគ្គីភាពការងារកម្ពុជា**

- **សហព័ន្ធសហជីពអំណាចកម្មករខ្មែរ**

ទូរស័ព្ទ ៖ ០១៥ ៧២៨ ៤៧២/០៩២ ៩៥៧ ៤៧២ ទូរសារ ៖ គ្មាន

តំណាងកម្មករនិយោជិតចូលរួមប្រជុំមុនសវនាការ ៖ អវត្តមាន



ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ: ៨៥៥ ២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh • Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org • Website: www.arbitrationcouncil.org

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- ស្នើកុំឱ្យក្រុមហ៊ុនមានការរើសអើងចំពោះថ្នាក់ដឹកនាំសហជីពសាមគ្គីភាពការងារកម្ពុជា និងសហជីពអំណាចកម្មករខ្មែរប្រចាំក្រុមហ៊ុន ។

២- ស្នើសុំឱ្យក្រុមហ៊ុនផ្តល់អាហារសម្រាប់ពេលថ្ងៃត្រង់មួយពេលជូនដល់កម្មករវិញ ដូចពេលកន្លងមក ឬស្នើសុំជាប្រាក់ចំនួន ៤០០០ រៀល ក្នុងមួយថ្ងៃ ។

៣- ក្នុងករណីដែលក្រុមហ៊ុនគ្មានការងារធ្វើ ហើយឱ្យកម្មករចេញម៉ោង ៤៖០០ នាទី ស្នើឱ្យក្រុមហ៊ុន មានឡានជូនពួកគាត់ទៅផ្ទះផង កុំឱ្យពួកគាត់រងចាំរហូតដល់ម៉ោង ៦ ឬ ម៉ោង ៨ យប់ដូចពេលកន្លងមក ។

៤- ស្នើសុំប្រាក់បាយសម្រាប់ការបន្ថែមម៉ោងចាប់ពីម៉ោង ៤៖០០ ដល់ម៉ោង ៦៖០០ ចំនួន ៤០០០ រៀល និងពីម៉ោង ៦៖០០ នាទី ឡើងទៅ មួយម៉ោងស្មើនឹង ២០០០ រៀល ហើយបើកក្នុងមួយសប្តាហ៍ម្តង ។

៥- ស្នើសុំកុំឱ្យក្រុមហ៊ុនកាត់ប្រាក់ឈ្នួល និងប្រាក់រង្វាន់ផ្សេងៗចំពោះកម្មករសុំច្បាប់ ដែលបានសុំច្បាប់សម្រាកដោយមានជំងឺ ហើយមានសំបុត្រពេទ្យបញ្ជាក់ច្បាស់លាស់ពីគ្រូពេទ្យ ។

៦- ចំពោះគ្រោះថ្នាក់ការងារ ស្នើសុំឱ្យក្រុមហ៊ុនចេញថ្លៃព្យាបាលទាំងអស់ជំនួសកម្មករ ទោះបីគាត់សំរាកនៅមន្ទីរពេទ្យណាក៏ដោយ ។

៧- ស្នើសុំឱ្យក្រុមហ៊ុនរៀបចំប្រព័ន្ធទឹកប្រើប្រាស់ និងទឹកផឹកឱ្យបានគ្រប់គ្រាន់ និងមានអនាម័យល្អ ។

៨- សុំឱ្យក្រុមហ៊ុនរៀបចំឱ្យមានពេទ្យនៅប្រចាំការរាល់ម៉ោងកម្មករធ្វើការ និងឱ្យមានថ្នាំពេទ្យគ្រប់គ្រាន់សម្រាប់ការជួយសង្គ្រោះបឋមដល់កម្មករដែលមានជំងឺ ។

៩- ស្នើសុំឱ្យក្រុមហ៊ុនផ្ទៀងផ្ទាត់ប្រាក់ឱ្យបានត្រឹមត្រូវមុននឹងបើកជូនកម្មករ ។

១០- ការប្រើប្រាស់ច្បាប់ពិសេស ស្នើសុំឱ្យក្រុមហ៊ុនកុំកាត់ប្រាក់ឈ្នួលប្រចាំថ្ងៃ និងប្រាក់រង្វាន់ផ្សេងៗរបស់កម្មករ គឺសុំកាត់ត្រឹមតែប្រាក់បំណាច់ឆ្នាំបានហើយ ។

១១- ស្នើសុំឱ្យក្រុមហ៊ុនចេញថ្លៃបង់ពន្ធលើប្រាក់ឈ្នួលជូនរដ្ឋជំនួសកម្មករ ។

១២- ចំពោះស្ត្រីមានផ្ទៃពោះ ស្នើសុំបានចេញមុនម៉ោងចំនួន ១៥ នាទី ដើម្បីជៀសវាងគ្រោះថ្នាក់ ។

១៣- ស្នើសុំអនុញ្ញាតឱ្យស្ត្រីមានផ្ទៃពោះបានឈប់សំរាកបានមួយថ្ងៃក្នុងមួយខែ ដើម្បីទៅពិនិត្យផ្ទៃពោះដោយរក្សាប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗនៅដដែល ។

១៤- ស្នើសុំឱ្យក្រុមហ៊ុនសាងសង់ទារកដ្ឋាន និងផ្តល់ថ្លៃទឹកដោះគោចំនួន ២៥ ដុល្លារ ក្នុងមួយខែ ជូនដល់ កម្មការិនីបន្ទាប់ពីសំរាលកូនហើយ ។

១៥- ក្រុមហ៊ុនមិនត្រូវបង្ខំកម្មករឱ្យធ្វើការបន្ថែមម៉ោងឡើយ ត្រូវអនុវត្តតាមគោលការណ៍ស្ម័គ្រចិត្ត ។

១៦- ស្នើសុំឱ្យក្រុមហ៊ុនជួយសម្រួលច្បាប់ឱ្យមានភាពងាយស្រួលជូនដល់កម្មករ នៅពេលដែលគាត់ឈប់ដោយ

THE ARBITRATION COUNCIL

មានធុរៈ ដោយមិនចាំបាច់កំណត់ចំនួនថ្ងៃឈប់សម្រាកបានតែពីរថ្ងៃប៉ុណ្ណោះទេ។

១៧- ស្នើសុំឱ្យក្រុមហ៊ុនរៀបចំឱ្យមានជាពិធីជប់លៀងប្រចាំឆ្នាំក្នុងមួយឆ្នាំម្តង និងរៀបចំរៀងរាល់ឆ្នាំជូនដល់កម្មករ កម្មការិនីទាំងអស់។

១៨- សុំឱ្យក្រុមហ៊ុនរក្សាប្រាក់ឈ្នួល និងប្រាក់រង្វាន់ផ្សេងៗក្នុងអំឡុងពេលធ្វើកូដកម្ម។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ(ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាស លេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៥៥ កប/ប្រក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ (អាណត្តិទី១១)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ៤០៤ កប/អក/វក ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៤ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៤។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទជួបប្រជុំមុនសវនាការ ៖** ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤ (វេលាម៉ោង ០៨ និង ០០ នាទី រសៀល )។

**បញ្ហានៃនីតិវិធី ៖**

នៅថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៤ នាយកដ្ឋានវិវាទការងារបានទទួលបណ្តឹងតាមទូរស័ព្ទពីសហព័ន្ធសហជីពសាមគ្គីភាពការងារកម្ពុជា និងសហព័ន្ធសហជីពអំណាចកម្មករខ្មែរ ស្តីពីការធ្វើកូដកម្មទាមទារឱ្យក្រុមហ៊ុនកែលំអនូវលក្ខខណ្ឌការងារមួយចំនួនឱ្យបានល្អប្រសើរ។ ក្រោយពីបានទទួលបណ្តឹងនេះមក នាយកដ្ឋានវិវាទការងារបានចាត់មន្ត្រីជំនាញឱ្យធ្វើការដោះស្រាយវិវាទការងាររួមនេះភ្លាម និងបានធ្វើការផ្សះផ្សា នៅថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៤ ដោយទទួលបានលទ្ធផលមិនសះជានឹងគ្នាចំនួន ១៨ ចំណុច លើការទាមទារចំនួន ១៨ ចំណុច។ ចំណុចមិនសះជាចំនួន ១៨ ចំណុច ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៤ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន កូកូរ៉ុល អឹកែរីល (ខេមបូឌា) អ៊ិន លេខ ៤០៤ ក.ប/អក/វក. ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៤។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលព័ត៌មានថា កូដកម្មនៅតែបន្ត បន្ទាប់ពីសំណុំរឿងត្រូវបានបញ្ជូនមក ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលលិខិតមួយច្បាប់របស់ក្រុមហ៊ុន កូកូរ៉ុល អឹកែរីល

THE ARBITRATION COUNCIL

(ខេមបូឌា) អ៊ីន ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៤ ស្តីពីសំណើសុំក្រុមប្រឹក្សាអាជ្ញាកណ្តាល ចេញសេចក្តីបង្គាប់បញ្ជា បញ្ឈប់ការធ្វើកូដកម្មជាបន្ទាន់ ដែលការធ្វើកូដកម្មរបស់កម្មករនិយោជិតបានចាប់ផ្តើមពីថ្ងៃទី០៤ ខែមេសា ឆ្នាំ ២០១៤ រហូតដល់ថ្ងៃនេះ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបញ្ជា លេខ ០២០/១៤ កបអ. ចុះ ថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៤ ឱ្យកូដករផ្អាកជាបន្ទាន់នូវការធ្វើកូដកម្មរបស់កម្មករនិយោជិតនៃក្រុមហ៊ុន កូកូវ៉ុល អ៊ីភែរីល (ខេមបូឌា) អ៊ីន រហូតដល់នីតិវិធីនៃអាជ្ញាកណ្តាលត្រូវបានចប់សព្វគ្រប់តាមនីតិវិធីច្បាប់ ហើយកូដករទាំង អស់ត្រូវត្រឡប់ចូលធ្វើការវិញ ចាប់ពីរសៀលថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៤ តទៅតាមវេនរបស់ខ្លួន។ យ៉ាងណាមិញ ក្រោយការចេញសេចក្តីបញ្ជានេះ កូដករនៅតែបន្តធ្វើកូដកម្មដដែល ដោយកូដករមិនបានគោរពតាមសេចក្តីបញ្ជា របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនេះទេ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានអញ្ជើញភាគីទាំងពីរមកសាកសួរ ព័ត៌មានបន្ថែម នៅក្នុងកិច្ចប្រជុំមុនសវនាការអាជ្ញាកណ្តាលនៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ វេលាម៉ោង ៨៖០០ នាទីព្រឹក។ ភាគីនិយោជកមានវត្តមាន តាមការអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ប៉ុន្តែ ភាគីកម្មករនិយោជិត មិនមានវត្តមានចូលរួម តាមការអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ។

មុនកិច្ចប្រជុំមុនសវនាការអាជ្ញាកណ្តាលនៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ នាវេលាម៉ោង ៧៖៤០នាទីព្រឹក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលព័ត៌មានតាមរយៈទូរស័ព្ទពីលោក សៀង រិទ្ធី ជាប្រធានសហព័ន្ធ សហជីពសាមគ្គីភាពការងារកម្ពុជា និងលោក សុខ សុខហួត ជាអនុប្រធានសហព័ន្ធសហជីពអំណាចកម្មករខ្មែរ បាន បញ្ជាក់តាមទូរស័ព្ទមកកាន់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលថា កម្មករនៅបន្តធ្វើកូដកម្ម ។ ចំណែកឯភាគី និយោជក ឈ្មោះ ប្រៃស ផល្លី ជាប្រធានរដ្ឋបាលបានបញ្ជាក់នៅក្នុងកិច្ចប្រជុំមុនសវនាការអាជ្ញាកណ្តាលថា បន្ទាប់ពី ក្រុមប្រឹក្សាអាជ្ញាកណ្តាលចេញសេចក្តីបញ្ជា លេខ ០២០/១៤ កបអ កម្មករនិយោជិតភាគច្រើន បានចូលធ្វើការវិញ ប៉ុន្តែ កម្មករនិយោជិតមួយចំនួនទៀតមិនបានចូលធ្វើការទេ ថែមទាំងបានគំរាមកំហែងកម្មករនិយោជិតដទៃមិនឱ្យ ចូលធ្វើការទៀតផងដែរ ។ ភាគីនិយោជកបានបញ្ជាក់បន្ថែមថា ភាគីកម្មករនិយោជិតកូដកម្មនៅតែបន្ត។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា ដូចខាងក្រោម ៖

**តស្តុតាង**

**សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន**

**ឯកសារ វត្ថុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

១- ពាក្យសុំឱ្យចេញលិខិតបញ្ជារបស់ក្រុមហ៊ុន កូកូវ៉ុល អ៊ីភែរីល (ខេមបូឌា) អ៊ីន ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៤ គោរពជូន ប្រធានក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសំណើសុំឱ្យប្រធានក្រុមប្រឹក្សាអាជ្ញាកណ្តាល ចេញលិខិតបញ្ជាបញ្ឈប់ធ្វើកូដកម្មជាបន្ទាន់។

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖ គ្មាន

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន កូកូវ៉ុល អ៊ីភែរីល (ខេមបូឌា) អ៊ីន លេខ

THE ARBITRATION COUNCIL

៤០៤ កប/អក/វក ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៤។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន កូកូរ៉ុល អឹភែរឹល (ខេមបូឌា) អ៊ិន ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៤។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- សេចក្តីបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០២០/១៤ កបអ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៤។

២- លិខិតអញ្ជើញភាគីនិយោជកចូលរួមផ្តល់ព័ត៌មាន លេខ ៤៦០ កប/អក/វក/លកអ. ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៤។

៣- លិខិតអញ្ជើញភាគីនិយោជិតចូលរួមផ្តល់ព័ត៌មាន លេខ ៤៦១ កប/អក/វក/លកអ. ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៤។

**អង្គហេតុ**

- មិនមានការរកឃើញអង្គហេតុ ទាក់ទងទៅនឹងចំណុចបញ្ហាវិវាទនៅក្នុងរបាយការណ៍មិនសះជា ដែលនាយកដ្ឋានវិវាទការងារបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ ដោយសារក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនបានដំណើរការសវនាការ។

**ហេតុផលនៃសេចក្តីសម្រេច ÷**

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើត្រូវបន្តនីតិវិធីអាជ្ញាកណ្តាលដែរ ឬទេ?

ប្រការ ២០ នៃប្រកាសលេខ ០៩៩ សកបយ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលចែងថា៖ "*ក្នុងអំឡុងពេលនៃដំណើរការរបស់ក្រុមអាជ្ញាកណ្តាល ភាគីវិវាទទាំងឡាយត្រូវផ្អាករាល់វិធានការវិវាទ ដូចជាកូដកម្ម ឬឡុកអៅ (ដូចមានចែងក្នុងមាត្រា ៣១៨ នៃច្បាប់ស្តីពីការងារ) ឬវិធានការដទៃទៀត ដែលអាចធ្វើឱ្យស្ថានភាពវិវាទកាន់តែធ្ងន់ធ្ងរ។ ភាគីទាំងនេះត្រូវតែចូលរួមគ្រប់កិច្ចប្រជុំទាំងឡាយ ដែលក្រុមអាជ្ញាកណ្តាលបានអញ្ជើញឱ្យចូលរួម*"។

យោងតាមប្រការ ២០ នៃប្រកាសលេខ ០៩៩ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីវិវាទត្រូវផ្អាករាល់វិធានការវិវាទ ដូចជាកូដកម្ម ឬឡុកអៅ ឬវិធានការដទៃទៀត ដែលអាចធ្វើឱ្យស្ថានភាពវិវាទកាន់តែធ្ងន់ធ្ងរ នៅក្នុងដំណើរការអាជ្ញាកណ្តាល។

នៅក្នុងសេចក្តីបង្គាប់មុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយមាត្រានេះថា ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងមិនបន្តដំណើរការអាជ្ញាកណ្តាលទេ នៅពេលណាភាគីកម្មករនិយោជិត កំពុងធ្វើកូដកម្ម ឬនិយោជកធ្វើឡុកអៅ។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ *៥៩/០៦-សាង វ៉ី, លេខ ៣៩/០៨-ចុង យ៉ុវ, លេខ ១៣៧/០៨, ១៣៨/០៩-ញ៉ូ ភាញ់, លេខ ១១០/១១-ស៊ីម៉ាណ្ឌ, លេខ ១០៨/១៣-សាប្រ៊ីណា (ខេមបូឌា), លេខ ១១៩/១៣-ញូ យៀន, និងលេខ ០១៩/១៤-ដុងឌូ ថេកស្តាយ (ខេមបូឌា)*)

នៅក្នុងសំណុំរឿងលេខ ០៤/០៤-អិម អេស អាយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តី ជូនដំណឹងមួយ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៤ ដែលកថាខ័ណ្ឌទី៤ នៃសេចក្តីជូនដំណឹងនេះ កំណត់ថា ៖

*"ដោយពិនិត្យឃើញថា ភាគីនៃវិវាទការងារនេះមិនមានសិទ្ធិធ្វើកូដកម្ម ក្នុងកំឡុងពេលនៃដំណើរការរបស់អាជ្ញាកណ្តាល ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចធ្វើការដោះស្រាយ ឬក៏ចេញសេចក្តីបង្គាប់លើវិវាទការងាររួមនេះបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលឡើយ ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចដោះស្រាយវិវាទការងាររួមនេះម្តងទៀតបាន នៅពេលណាដែលសហជីពកម្មករនិយោជិតទាំងអស់ឈប់ធ្វើកូដកម្ម "*។

ដូចគ្នាដែរ នៅក្នុងសំណុំរឿងលេខ ១៨/០៤-សណ្ឋាគារ (កាំបូឌីយ៉ាណា, រ៉ាហ្វែល ឡឺរ៉ូយ៉ាល់, រ៉ាហ្វល ប្រែគ្ន ឌិ អង្គរ, សាន់វេ, អ៊ិនធើខនធីណេនថល និងសូហ្វីតែល អង្គរ) ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបញ្ជាទីពីរ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៤ ដែលចំណុចទី៩ និងទី១១ នៃសេចក្តីបញ្ជានេះ ចែងដូចខាងក្រោម ៖

*" ចំណុចទី៩- ចាប់ពីថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៤ តទៅ កម្មករនិយោជិតទាំងអស់ត្រូវបញ្ឈប់កូដកម្ម បាតុកម្ម ឬការរំខានណាមួយ នៅក្នុងបរិវេណសណ្ឋាគារនានា ដែលជាភាគីនៃវិវាទនេះ "* ។

*" ចំណុចទី ១១-ក្រុមប្រឹក្សាអាជ្ញាកណ្តាលរក្សាសិទ្ធិក្នុងការបញ្ចប់ដំណើរការអាជ្ញាកណ្តាល ករណីដែលភាគីណាមួយបំពានប្រការណាមួយនៃសេចក្តីបញ្ជានេះ "* ។

នៅក្នុងសំណុំរឿងលេខ ៧៧/០៥-ហ្វ្រង់កូ នីតធីង ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបញ្ជាទី២ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០៥ ហើយបានចែងនៅក្នុងចំណុចទី៤ ថា នៅក្នុងករណីដែលភាគីកម្មករនិយោជិតបន្តធ្វើកូដកម្ម ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងមិនដំណើរការដោះស្រាយវិវាទការងាររួមនេះទេ ។

នៅក្នុងសំណុំរឿងលេខ ១១០/១១-ស៊ីម៉ាណូ និងសំណុំរឿងលេខ ១៧/១៣-អ៊ិនធើណាស្យូណាល់ ហ្វេសិន រ៉ូយ៉ាល់ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏បានចេញសេចក្តីបង្គាប់បញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយមូលហេតុ កម្មករនិយោជិតនៅតែបន្តធ្វើកូដកម្ម ក្នុងអំឡុងពេលដំណើរការនីតិវិធីរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលដែរ ។

នៅក្នុងសំណុំរឿង ០៦៦/១៤ - កាល់លីស្តូ អឺភេរីល (ខេមបូឌា) ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានសម្រេចចេញសេចក្តីបង្គាប់បញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយហេតុថា កម្មករនិយោជិតនៅតែបន្តធ្វើកូដកម្ម ដោយមិនគោរពតាមសេចក្តីបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងនេះ ក៏យល់ស្របតាមការសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងខាងលើដែរ ។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានអញ្ជើញភាគីទាំងពីរមកសាកសួរព័ត៌មានបន្ថែម នៅក្នុងកិច្ចប្រជុំមុនសវនាការអាជ្ញាកណ្តាលនៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ វេលាម៉ោង ៨៖០០ នាទីព្រឹក ។ ភាគីនិយោជកមានវត្តមាន តាមការអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ប៉ុន្តែ ភាគីកម្មករ និយោជិតមិនមានវត្តមានចូលរួម តាមការអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ ។

មុនកិច្ចប្រជុំមុនសវនាការអាជ្ញាកណ្តាល នៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ នាវេលាម៉ោង ៧៖៤០នាទីព្រឹក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលព័ត៌មានតាមរយៈទូរស័ព្ទពីលោក សៀង រិទ្ធី ជាប្រធានសហ

ព័ន្ធ សហជីពសាមគ្គីភាពការងារកម្ពុជា និងលោក សុខ សុខហួត ជាអនុប្រធានសហព័ន្ធសហជីពអំណាចកម្មករខ្មែរ បាន បញ្ជាក់តាមទូរស័ព្ទមកកាន់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលថា កម្មករនៅបន្តធ្វើកូដកម្ម ។ ចំណែកឯភាគីនិយោជកឈ្មោះ ប្រែស ផល្លី ជាប្រធានរដ្ឋបាលបានបញ្ជាក់នៅក្នុងកិច្ចប្រជុំមុនសវនាការអាជ្ញាកណ្តាលថា បន្ទាប់ពីក្រុមប្រឹក្សាអាជ្ញាកណ្តាលចេញសេចក្តីបញ្ជា លេខ ០២០/១៤ កបអ កម្មករនិយោជិតភាគច្រើនបាន ចូលធ្វើការវិញ ប៉ុន្តែ កម្មករនិយោជិតមួយចំនួនទៀតមិនបានចូលធ្វើការទេ ថែមទាំងបានគំរាមកំហែងកម្មករនិយោជិតដទៃមិនឱ្យចូលធ្វើការដែរ ។ ភាគីនិយោជកបានបញ្ជាក់បន្ថែមថា ភាគីកម្មករនិយោជិតកូដកម្មនៅតែបន្ត ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កម្មករនិយោជិតនៅតែបន្តធ្វើកូដកម្ម ដោយមិនគោរពតាមសេចក្តីបញ្ជាលេខ ០២០/១៤ កបអ. របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៤ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចបន្តនីតិវិធី និងដំណើរការសវនាការបានទេ ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបញ្ចប់ដំណើរការអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ។

យោងតាមអង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចដូចតទៅ ៖

## សម្រេច និង បង្គាប់

- បញ្ចប់ដំណើរការអាជ្ញាកណ្តាលក្នុងសំណុំរឿងលេខ ០៩២/១៤-កូកូរ៉ុល អីភេរីល (ខេមបូឌា) អ៊ីន (សាខាទី២) ។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក**

ឈ្មោះ ៖ **អ៊ុំ សុវិធី**

ហត្ថលេខា ៖ ------------------------------

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត**

ឈ្មោះ ៖ **លឹម សុវណ្ណា**

ហត្ថលេខា ៖ ------------------------------

**ប្រធានក្រុមអាជ្ញាកណ្តាល**

ឈ្មោះ ៖ **ម៉ែន ប៊ុនឈា**

ហត្ថលេខា ៖ ------------------------------

ក្រុមប្រឹក្សាអាជ្ញាកណ្តាល THE ARBITRATION COUNCIL